NO.


ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)
ព្រះរាជាណាចក្រកម្ពុជា
សាលាក្រុងភ្នំពេញ


# ការសិក្សាស្តីពី
# ការគ្រប់គ្រងសំណល់រឹងក្នុងរាជធានីភ្នំពេញ
# ក្នុងព្រះរាជាណាចក្រកម្ពុជា

## របាយការណ៍សង្ខេបបញ្ចប់








ខែមិនា ឆ្នាំ ២០០៥

KOKUSAI KOGYO CO., LTD.

GE
JR
05-008

នៅក្នុងរបាយការណ៍នេះ គំរោងបានធ្វើការប៉ាន់ស្មាននាស្ថានភាពខែ ធ្នូ ឆ្នាំ ២០០០៤ និងប្រើប្រាស់អត្រាផ្តូរប្រាក់ដែលមាន ១ ដុល្លាស្មើនិង ៤,០០០ រៀល និងស្មើ១០៤.៨៧៨ យ៉េនជប៉ុន ។

# អារម្ភកថា

ជាការឆ្លើយតបទៅនឹងសំណើររបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា រដ្ឋាភិបាលនៃប្រទេសជប៉ុនបានសំរេចផ្តល់ការសិក្សាមួយលើការគ្រប់គ្រងសំណល់រឹងនារាជធានីភ្នំពេញ ហើយបានប្រគល់ការទទួលខុសត្រូវលើការសិក្សានេះ ជូនដល់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេស ជប៉ុន (**JICA**) ។

JICA បានជ្រើសរើសក្រុមសិក្សាមួយដែលដឹកនាំដោយលោក Junji Anai នៃក្រុមហ៊ុន KOKUSAI KOGYO CO.,LTD និងបានបញ្ជូនក្រុមសិក្សាមកប្រទេសកម្ពុជាចំនួនបួនលើកមកហើយក្នុងចន្លោះពីខែកុម្ភៈ ឆ្នាំ ២០០៣ រហូតដល់ខែមករា ឆ្នាំ២០០៥ ។

ជាងនេះទៅទៀត **JICA** បានបង្កើតគណៈកម្មាធិការផ្តល់ការប្រឹក្សាមួយដែលដឹកនាំដោយបណ្ឌិត Hidetoshi Kitawaki ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យតូយ៉ូ ដែលបានធ្វើការត្រួតពិនិត្យលើការសិក្សានៃក្រុមសិក្សានេះ យោងលើផ្នែកជំនាញ និងបច្ចេកទេស ។

ក្រុមសិក្សាបានពិភាក្សាជាមួយមន្ត្រីពាក់ព័ន្ធរបស់រដ្ឋាភិបាលកម្ពុជា និងបានធ្វើការសិក្សាស្ទង់មតិនៅក្នុងតំបន់សិក្សាផងដែរ ។ ពេលត្រឡប់មកប្រទេសជប៉ុនវិញ ក្រុមសិក្សាបានរៀបចំរបាយការណ៍បញ្ចប់នេះឡើង ។

ខ្ញុំសង្ឃឹមជឿជាក់ថា របាយការណ៍នេះនឹងចូលរួមចំណែកសំរាប់ការអនុវត្តនលើផែនការនេះ និងជាការរឹតចំណងសាមគ្គីភាពរវាងប្រទេសយើងទាំងពីរ ។

ជាទីបញ្ចប់ ខ្ញុំសូមសំដែងនូវសេចក្តីកោតសសើរដ៏ស្មោះស័គ្រចំពោះមន្ត្រីពាក់ព័ន្ធរបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សំរាប់សហប្រតិបត្តការដ៏ប្រពៃក្នុងការសិក្សាកន្លងមក ។

ខែមិនា ឆ្នាំ២០០៥

**Etsuo KITAHARA**

អនុប្រធាន

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន

**Mr. Etsuo KITAHARA** **March 2005**
Vice President
Japan International Cooperation Agency

# លិខិតផ្ទេរ

លោក **KITAHARA,**

យើងខ្ញុំមានបតិសោមនស្សរីករាយសូមដាក់ជូននូវរបាយការណ៍បញ្ចប់ នៃការសិក្សាលើការគ្រប់គ្រង សំណល់រឹងនារាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ។

របាយការណ៍នេះរួមមានផ្នែកសំខាន់បីគឺ : ការសិក្សាលើការអនុវត្តន៏នាពេលបច្ចុប្បន្ននៃការគ្រប់គ្រង សំណល់រឹង ផែនការមេលើការគ្រប់គ្រងសំណល់រឹងរហូតឆ្នាំ ២០១៥ និងការសិក្សាលើគំរោងអទិភាពនានា ។

បញ្ហាជាច្រើននាពេលបច្ចុប្បន្នត្រូវបានរកឃើញតាមរយះការវិភាគទិន្នន័យដែលមានស្រាប់ និងការវាយតំលៃលើលទ្ធផលលៃការសិក្សាអង្កេតចំនួន ១១ប្រភេទដែលបានធ្វើឡើងក្នុងរយះនៃពេលសិក្សា ។ យើងបានកំណត់ទិសដៅជាមូលដ្ឋានមួយគឺ បង្កើតប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងមួយដែលមាននិរន្តរភាពសំរាប់រាជធានី ភ្នំពេញរហូតដល់ឆ្នាំ ២០១៥ ដែលជាឆ្នាំទិសដៅ ហើយបានស្នើរថា តំបន់ដែលមិនមានសេវាកម្ម និងតំបន់មាន សេវាកម្មតែមិនទាន់សមស្របគួរតែត្រូវបានលុបបំបាត់ចោលពីទីក្រុង ក្រោមកិច្ចសហការរវាងស្ថាប័នសាធារណ និងឯកជន ។ យើងក៏បានរៀបចំផែនការទីលានចាក់សំណល់មួយសំរាប់ចាក់សំណល់ដែលបានប្រមូល ដោយមិនអោយមានផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន ។ ជាងនេះទៀត យើងបានធ្វើការសិក្សាលើគំរោងអភិវឌ្ឍន៏ទីលានថ្មី គំរោងពង្រីកសេវាកម្មប្រមូលសំណល់ និងគំរោងការបិទទីលានបច្ចុប្បន្ន ដែលយល់ឃើញថាជាគំរោងអទិភាព ។ ភាពច្បាស់លាស់នៃការអនុវត្តន៏គំរោងទាំងនេះត្រូវបានគេពិនិត្យដោយយកចិត្តទុកដាក់លើបញ្ហា បច្ចេកទេស សង្គម បរិស្ថាន ហិរញ្ញវត្ថុ និងផ្នែកសេដ្ឋកិច្ច ។

ជាបន្ថែមលើការសិក្សាខាងលើ យើងបានរៀបចំធ្វើគំរោងសាកល្បងនានាដូចជា ការកែលំអរទីលានស្ទឹង មានជ័យ គំរោងពង្រីកសេវាកម្មប្រមូលសំណល់ យុទ្ធនាការអប់រំជាសាធារណះសំដៅពង្រឹងសមត្ថភាពរបស់ សមភាគីលើការគ្រប់គ្រងសំណល់រឹង ។ សមភាគីកំពុងអនុវត្តន៏ការណែនាំពីការសិក្សានេះ ហើយបានចែករំលែក និងអភិវឌ្ឍន៏ការផ្ទេរបច្ចេកវិទ្យាដោយខ្លួនឯង ដែលហាក់ដូចជាកំពុងទទួលបាននូវផ្លែផ្កា ។

យើងខ្ញុំសូមឆ្លៀតយកឱកាសដ៏ប្រពៃនេះ ដើម្បីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ស្ថាប័ន របស់លោកស្រី ក្រសួងការបរទេស និងក្រសួងបរិស្ថាននៃប្រទេសជប៉ុនផងដែរ ។ យើងខ្ញុំក៏សូមសំដែងនូវសេចក្តីកោតសសើរដ៏ស្មោះស័គ្រចំពោះមន្ត្រីពាក់ព័ន្ធរបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្ថានទូតជប៉ុន និង ការិយាល័យអង្គការចាយកាកម្ពុជា សំរាប់សហប្រតិបត្តការដ៏ប្រពៃក្នុងការសិក្សាកន្លងមក ។

ជាចុងក្រោយនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលនៃការសិក្សានេះនឹងក្លាយជាវិភាគទានមួយសំរាប់ការអភិវឌ្ឍន៏ប្រកបដោយនិរន្តរភាព មិនតែចំពោះទីក្រុងភ្នំពេញប៉ុណ្ណោះទេ តែទូទាំងប្រទេសកម្ពុជា ទាំងមូល ។

ដោយក្តីគោរព

**Junji ANAI**

ប្រធានក្រុមសិក្សា

លើការគ្រប់គ្រងសំណល់រឹងនារាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា

# ចំនុចសំខាន់ ៗ របស់ផែនការមេ

## 1. គោលបំណង

(ក) បង្កើតផែនការមេ (បន្ទាប់ទៅនេះមានអក្សរកាត់គឺ "ផ.ម") គ្រប់គ្រងសំណល់រឹងក្នុងភ្នំពេញជាមួយឆ្នាំគោលដៅ ២០១៥ ។

(ខ) ដឹកនាំការសិក្សាលទ្ធភាព(បន្ទាប់ទៅនេះមានអក្សរកាត់គឺ"ស.ល")សំរាប់ជ្រើសរើសគំរោងជាអាទិភាព ។

(គ) ផ្ទេរបច្ចេកវិទ្យាដល់សមភាគី (បន្ទាប់ទៅនេះមានអក្សរកាត់គឺ "ស.ភ") នៅក្នុងវគ្គសិក្សា ។

## 2. តំបន់សិក្សា

តំបន់សិក្សារួមបញ្ចូលនៅក្នុងទីក្រុងទាំងមូល( ប្រជាជនប្រហែល១,២លាននាក់ និងផ្ទៃ៣៧៣,៧៣ គ.ម២ ) ។

## 3. សំណល់ក្នុងតំបន់សិក្សា

សំនល់ដែលមានក្នុងតំបន់សិក្សាភាគច្រើនជាសំនល់ផ្ទះបាយ ល្វ (កាកសំណល់រាវប្រមូលពីអាងអនាម័យ ) និងសំនល់ឧស្សាហកម្ម និងវេជ្ជសាស្ត្រ ។ តែទោះជាយ៉ាងណា ក្រុមសិក្សាមិនបានពិចារណារទាំងស្រុងលើប្រភេទទាំងបីនោះទេក្នុងផែនការមេ តែបានសិក្សាលើលក្ខណ៍នាពេលបច្ចុប្បន្ន លើបញ្ហានានា និងចំនុចដែលនឹងត្រូវដោះស្រាយ ។

## 4. ៤ៗ ផែនការមេ

ទិសដៅសំខាន់គឺ *"ការបង្កើតប្រព័ន្ធគ្រប់គ្រងសំណល់រឹងប្រកបដោយនិរន្តរភាពនាទីក្រុងភ្នំពេញអោយបាននាឆ្នាំ ២០១៥"* ។ ដើម្បីឈានអោយបានសំរេចផែនការនេះជាជំហ៊ាននោះ ផែនការត្រូវចែកជាបីតំណាក់កាល :

**ដំណាក់កាលទី ១:** ២០០៥ ដល់ ឆ្នាំ២០០៧។ ទីលានថ្មីត្រូវធ្វើការអភិវឌ្ឍន៍ស្របពេលដែលទីលានចាស់ត្រូវបានកែលំអរ។
ប្រព័ន្ធប្រមូលសំនល់ក៏ត្រូវបានបង្កើតក្រោមការសហការរវាងស្ថាប័នសាធារណ
និងឯកជន ។

**ដំណាក់កាលទី ២:** ឆ្នាំ ២០០៨ ដល់ ឆ្នាំ ២០១២ (ការកែលំអររយះពេលខ្លី)។ ទីលាន និងប្រព័ន្ធប្រមូលដែលស្ថាបនានាតំណាក់កាលទីមួយនោះ
នឹងត្រូវអនុវត្តនាពេលនេះអោយមានប្រសិទ្ធភាព ។

**ដំណាក់កាលទី ៣:** ឆ្នាំ ២០១៣ ដល់ ឆ្នាំ ២០១៥ (ការកែលំអររយះពេលមធ្យម)។ ផែនការមេត្រូវបានសំរេច ហើយការរៀបចំសំរាប់ស្តង់ដាប្រសើរជាងនេះនឹងត្រូវរៀបចំ ។

ដើម្បីសំរេចផែនការមេជា ជំហ៊ាន ៗនោះ គោលដៅតាម តំណាក់កាលត្រូវបានរៀបចំដូចតារាងខាងក្រោម :

តារាង ១: ទិសដៅជាទូរលេខនៃផែនការមេលើការគ្រប់គ្រងសំណល់នារាជធានីភ្នំពេញ

| ផ្នែកបច្ចេកទេស | បច្ចុប្បន្ន (2004) | Phase 1 (2007) | Phase 2 (2012) | Phase 3 (2015) |
|---|---|---|---|---|
| សេវាកម្មគ្រប់ដណ្តប់លើចំនួនប្រជាពលរដ្ឋ (សេវាកម្ម ជាមួយនិងបរិមាណសំនល់បញ្ចេញ) | | | | |
| ៤ ខណ្ឌប្រជុំជន | 95.6% (90.7%) | 97.8% (92.5%) | 100% (94.1%) | 100% (93.8%) |
| ៣ ខណ្ឌជនបទ | 53.4% (48.2%) | 73.4% (68.1%) | 88.8% (83.0%) | 95.7% (89.7%) |
| ការកាត់បន្ថយការបញ្ចេញ | | | | |
| អត្រាកំណើននៃសំនល់តាមផ្ទះ (ប្រភាគនៃសំនល់តាមផ្ទះ និងសំនល់សរុប) | 1.00 (63.0%) | 1.14 (62.6%) | 1.32 (61.5%) | 1.42 (60.9%) |
| អត្រាកំណើននៃសំនល់ពាណិជ្ជកម្ម (ប្រភាគនៃសំនល់ពាណិជ្ជកម្ម និងសំនល់សរុប) | 1.00 (37.0%) | 1.16 (37.4%) | 1.41 (38.5%) | 1.55 (39.1%) |
| ប្រភាគនៃសំនល់កែឆ្នៃ និងសំនល់សរុបដែលបញ្ចេញ | | | | |
| ៤ ខណ្ឌប្រជុំជន | 11.1 % | 14.6 % | 15.5 % | 16.0 % |
| ៣ ខណ្ឌជនបទ | 6.8 % | 8.3 % | 10.4 % | 11.7 % |
| ប្រភាគនៃសំនល់កំប៉ុស្ត (ប្រព្រឹត្តកម្មភ្លាម ៗ) និងសំនល់សរុបដែលបញ្ចេញ (តោន/ថ្ងៃ) | 0.1% (1.3) | 2.4% (26.3) | 2.0% (29.3) | 1.9% (32.3) |
| ប្រភាគនៃសំនល់ដែលចាក់ចោលមិនត្រឹមត្រូវ | | | | |
| ៤ ខណ្ឌប្រជុំជន | 2.2 % | 1.1 % | 0.0 % | 0.0 % |
| ៣ ខណ្ឌជនបទ | 13.8 % | 7.2 % | 1.8 % | 0.0 % |
| ការបោសសំអាតថ្នល់ | | | | |
| ៤ ខណ្ឌប្រជុំជន | 46km | 46km | 46km | 46km |
| ៣ ខណ្ឌជនបទ | 10km | 14km | 19km | 24km |
| របៀបចាក់សំណល់ផ្ទះបាយ | ទីលានចំហរ | ទីលានអនាម័យកំរិត ១ (ថ្លៃទីលាន) | ទីលានអនាម័យកំរិត ៤ | |

## 5. ៥២ គំរោងអទិភាព

ដើម្បីធ្វើការផ្ទៀងផ្ទាត់ផែមការមេដែលបានសិក្សា គេបានកំណត់យកគំរោងអទិភាពមួយចំនួនមកធ្វើការសាកល្បង ។

តារាង ២: គំរោងអទិភាព និងការវិនិយោគគ្រាតំបូង

| ឈ្មោះគំរោង | មាតិការ | Investment (2005 - 2006) | Investment (2007) |
|---|---|---|---|
| ១. គំរោងអភិវឌ្ឍន៍ទីលានដង្កោ | សាសង់ទីលានថ្មីជំហ៊ានទី ១: ៣១.៤ ហ.ត | 8,890 | 0 |
| | សាងសង់រោងជីកំប៉ុស | 1,194 | 0 |
| | សាងសង់រោងជាងថែទាំរថយន្ត | 1,574 | |
| | សរុបរង | **11,658** | **0** |
| ២. គំរោងពង្រីកសេវាកម្មប្រមូលសំណល់( រដ្ឋាករផ្តល់សេវាកម្មទោដល់កន្លែងដែលមិនមាន សេវា ) | | 1,804 | 195 |
| ៣. គំរោងបិទទីលានស្ទឹងមានជ័យ | | 75 | 745 |
| សរុប | | **13,537** | **940** |

## 6. ការផ្តល់អនុសាសន៏សំរាប់កែលំអរផែនការមេ

### 6.1 តំបន់ដែលមិនមាន ឬមានសេវាកម្មតែមិនទាន់សមស្រប

- សាលាក្រុង និងក្រុមហ៊ុនឯកជន (ស៊ីនទ្រី)គួរតែកំណត់តំបន់ដែលមិនមានសេវា ឬមានសេវាកម្មតែមិនទាន់សមស្របនៅក្នុងទីក្រុងហើយធ្វើវិសោធនកម្មលើកិច្ចសន្យាដើម្បីអោយរដ្ឋាករអាចផ្តល់សេវាកម្មទៅតំបន់ទាំងនោះ ។
- សាលាក្រុង/មន្ទីរបរិស្ថានគួរតែបង្កើតប្រព័ន្ធត្រួតពិនិត្រ និងតាមដានសេវាកម្មដែលផ្តល់ដោយរដ្ឋាករ និងក្រុមហ៊ុនឯកជន ។

### 6.2 ការបង្កើតទីលានចាក់សំណល់សមស្របមួយ

- រដ្ឋាករគួរតែបន្តគំរោងសាកល្បងសំរាប់ការកែលំអរទីលានស្ទឹងមានជ័យ ហើយអភិវឌ្ឍន៏សមត្ថភាពលើការងារគ្រប់គ្រងទីលាន ។
- រដ្ឋាករគួរតែបង្កើនកំរិតប្រតិបត្តការនៃទីលានអនាម័យស្ទឹងមានជ័យជាជំហ៊ាន ៗ ។
- រដ្ឋាករគួរតែពន្យល់ដល់អ្នកប្រើប្រាស់ទីលានអំពីផលចំណេញនៃការកែលំអរទីលាន ដោយធ្វើយ៉ាងណាអោយគេ យល់អំពីការបង្កើនថ្លៃទីលាន និងការឯកភាពបង់ថ្លៃសេវាទីលាន ។
- រដ្ឋាករគួរតែពន្យល់ដល់អ្នកប្រើប្រាស់ទីលានអោយព្យាយាមបង្កើនថ្លៃទីលានជាជំហ៊ាន ៗ ដើម្បីធានាលើការចំណាយនាទីលាន ។
- រដ្ឋាករគួរតែពន្យល់អំពីសកម្មភាពកែលំអរទីលានដល់មិនត្រឹមតែអ្នករស់នៅក្បែរទីលានទេ តែប្រជាជនទូទាំងរាជធានីភ្នំពេញដើម្បីចែករំលែកតំលៃគ្រប់គ្រងទីលានអនាម័យមួយ ។

## 6.3 ការបង្កើតទីលានចាក់សំណល់សមស្របមួយ

- ដោយយោងលើបញ្ហាលំបាកលើផ្នែកថវិកា ក្រុមសិក្សាបានណែនាំថាសាលាក្រុងត្រូវតែប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីធានាថវិការពីបរទេសដើម្បីការអនុវត្តគំរោងសាងសង់ទីលានដង្កោ និងសេវាកម្មប្រមូលសំរាម ។
- ដើម្បីអោយគមរោងមាននិរន្តរភាពផ្នែកសេដ្ឋកិច្ចដែលនឹងទទួលបានតែពីប្រាក់ប្រមូលពីការផ្តល់សេវាកម្ម សាលាក្រុងគួរតែធានាប្រព័ន្ធប្រាក់ចំណូលដែលលាមលំនិង ដោយយោងលើការបង្កើតអត្រាតំលៃសមស្រប និងមានតម្លា ភាពដល់អ្នកបង់ថ្លៃសេវាគ្រប់រូប ។
- សាលាក្រុងគួរតែព្យាយាមបន្តពន្យល់អំពីគំរោងអភិវឌ្ឍន៏ទីលានដង្កោ ដល់អ្នករស់នៅក្បែរទីលានថ្មីរហូតដល់តំណាក់កាលអនុវត្តតែម្តងដើម្បីធានាបានការឯកភាពជាសាធារណ និងការយល់អោយបានច្បាស់លាស់ពីគំរោង ។
- រដ្ឋាករគួរតែពិភាក្សាជាមួយនិងអ្នករើសសំរាមដែលរកចំណូលប្រចាំជីវិតជារាងរាល់ថ្ងៃ ដើម្បីរកវិធានការណ៏ដោះស្រាយនាពេលអនាគត ។
- ដើម្បីធានាការត្រួតពិនិត្រប្រតិបត្តការទីលានថ្មី មន្ទីរបរិស្ថានគួរតែបង្កើតគណកម្មការត្រួតពិនិត្រ ដោយមានការសហការណ៏ពីក្រសួងបរិស្ថាន ខណ្ឌ និងសង្កាត់ ប្រជាពលរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាល ។

## 6.4 ការទិញដីសំរាប់ការសាងសង់ហេដ្ឋារចនាសម្ព័នដែលចាំបាច់សំរាប់ ការអនុវត្តផែនការមេ

- សាលាក្រុងគួរតែទិញដីសំរាប់ប្រព្រឹត្តកម្មសំនល់ និងការចាក់សំណល់ដោយយោងលើយុទ្ធសាស្ត្រដែលបានកំណត់ក្នុងផ្នែកទី ៣ នៃរបាយការណ៏នេះ ។ តែទោះជាយ៉ាងណាការទិញដីនោះមានការលំបាកច្រើនដោយសារតែប្រជាជនយល់ថានេះមិនមែនជាបញ្ហារបស់គេ ។ សាលាក្រុងគួរតែធានាផ្ទៃក្រឡាបន្ថែមទៀត ។












| Area | Color | No. | Khan |
|---|---|---|---|
| Urban area | | 1<br>2<br>3<br>4 | Chamkar Mon<br>Daun Penh<br>Prampir Makara<br>Toul Kork |
| Rural area | | 501 - 515 | Dang Kor |
| | | 601 - 608 | Mean Chey |
| | | 701 - 712 | Russei Keo |

The Study on Solid Waste Management in the Municipality of Phnom Penh in the Kingdom of Cambodia

**Study Area**



Bird's-eye View: Proposed Dang Kor New Disposal Site